ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៥៧៧៥ សហវ.ប្រក

# ប្រកាស
# ស្តីពី
# ការដាក់ឱ្យអនុវត្តជំហានដំបូងប្រព័ន្ធបញ្ជរតែមួយជាតិ

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## ប្រធានគណៈកម្មាធិការដឹកនាំគម្រោងបញ្ជរតែមួយជាតិ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៦/០១៥ ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារស្តីពីក្របខ័ណ្ឌច្បាប់សម្រាប់អនុវត្តបញ្ជរតែមួយអាស៊ាន
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០០៦ ស្តីពីកិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យ
- បានឃើញអនុក្រឹត្យ ២០៩ អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៧ ស្តីពីការដាក់ឱ្យប្រើប្រាស់បញ្ជីទំនិញហាមឃាត់និងទំនិញជាប់កម្រិតកំណត់
- បានឃើញអនុក្រឹត្យ ១១១ អនក្រ.បក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៥ ស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យ១៤៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស
- បានឃើញអនុក្រឹត្យលេខ ២៥ អនក្រ.បក ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៥ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំគម្រោងបញ្ជរតែមួយជាតិ
- យោងតាមសំណូមពរការងារចាំបាច់របស់គណៈកម្មាធិការដឹកនាំគម្រោងបញ្ជរតែមួយជាតិ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទ: ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨

# សម្រេច

**ប្រការ ១.-**

ប្រកាសនេះមានគោលបំណង លើកកម្ពស់បន្ថែមទៀតនូវប្រសិទ្ធភាពនៃកិច្ចសម្រួលពាណិជ្ជកម្ម តាមរយៈការដាក់ឱ្យអនុវត្តប្រព័ន្ធបញ្ជរតែមួយជាតិ។

**ប្រការ ២.-**

ប្រកាសនេះមានគោលដៅ កំណត់នីតិវិធីនៃការស្នើសុំ និងការចេញអាជ្ញាប័ណ្ណ វិញ្ញាបនបត្រ ឬលិខិតអនុញ្ញាត តាមប្រព័ន្ធបញ្ជរតែមួយជាតិ សម្រាប់បម្រើឱ្យប្រតិបត្តិការនាំចេញ នាំចូល និងឆ្លងកាត់ទំនិញ។

**ប្រការ ៣.-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះការស្នើសុំអាជ្ញាប័ណ្ណ វិញ្ញាបនបត្រ ឬលិខិតអនុញ្ញាត ពាក់ព័ន្ធនឹងករណីដូចខាងក្រោម÷

- ទំនិញហាមឃាត់ និងជាប់កម្រិតកំណត់
- ទំនិញស្ថិតក្នុងកាតព្វកិច្ចនៃការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី
- ទំនិញស្ថិតក្នុងកាតព្វកិច្ចនៃការអនុវត្តអនុសញ្ញាឬកិច្ចព្រមព្រៀងអន្តរជាតិផ្សេងទៀត
- ផលិតផលតេលសិលា និងទំនិញនៃអគារលក់ទំនិញរួចពន្ធ
- ទំនិញទទួលបានការលើកលែងពន្ធនិង/ឬអាករ របស់គម្រោងវិនិយោគ
- ទំនិញទទួលបានការលើកលែងពន្ធអាកររបស់ក្រសួង-ស្ថាប័ន បេសកកម្មការទូត បេសកកម្មកុងស៊ុលបរទេស និងអង្គការជាតិ/អន្តរជាតិនានា
- ទំនិញទទួលបានការលើកលែងពន្ធអាករផ្សេងទៀត តាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ ៤.-**

ការស្នើសុំអាជ្ញាប័ណ្ណ វិញ្ញាបនបត្រ ឬលិខិតអនុញ្ញាត ត្រូវធ្វើឡើងដោយម្ចាស់ទំនិញ ឬតំណាងដែលទទួលបានការអនុញ្ញាតឱ្យបំពេញបែបបទក្នុងនាមម្ចាស់ទំនិញ។

ម្ចាស់ទំនិញ ឬតំណាង ត្រូវចុះឈ្មោះសុំគណនីប្រើប្រាស់ប្រព័ន្ធ តាមរយៈគេហទំព័រដែលមានអាសយដ្ឋាន “www.nsw.gov.kh” ដោយភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធ មានជាអាទិ៍ វិញ្ញាបនបត្រចុះបញ្ជីពន្ធដារ (អាករលើតម្លៃបន្ថែម-អតប) អត្តសញ្ញាណប័ណ្ណឬលិខិតឆ្លងដែនមានសុពលភាព និងឯកសារគាំទ្រផ្សេងទៀតក្នុងទម្រង់អេឡិកត្រូនិក តាមការកំណត់របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា។

ម្ចាស់ទំនិញ ឬតំណាងដែលមានគណនីប្រើប្រាស់ប្រព័ន្ធ អាចស្នើសុំអាជ្ញាប័ណ្ណ វិញ្ញាបនបត្រ ឬលិខិតអនុញ្ញាត តាមរយៈគេហទំព័រដែលមានអាសយដ្ឋាន “www.nsw.gov.kh” ដោយត្រូវបំពេញទិន្នន័យក្នុងប្រអប់ព័ត៌មាននៃប្រព័ន្ធបញ្ជរតែមួយជាតិ រួចភ្ជាប់ជាមួយនូវឯកសារគាំទ្រនានាក្នុងទម្រង់អេឡិកត្រូនិក តាមបទប្បញ្ញត្តិជាធរមាន។

ក្នុងករណីចាំបាច់ ម្ចាស់ទំនិញ ឬតំណាង អាចតម្រូវឱ្យដាក់ជូនអាជ្ញាធរមានសមត្ថកិច្ចនូវឯកសារគាំទ្រនានាក្នុងទម្រង់ក្រដាស ជាក្រោយបន្ទាប់ពីការស្នើសុំតាមប្រព័ន្ធបញ្ជរតែមួយជាតិ ក្នុងរយៈពេលសមស្រប ដែលកំណត់ដោយក្រសួង-ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ។

**ប្រការ ៥.-**

ក្រសួង-ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ មានភារកិច្ចពិនិត្យនិងសម្រេច លើការចេញអាជ្ញាប័ណ្ណ វិញ្ញាបនបត្រ ឬលិខិតអនុញ្ញាត ក្នុងទម្រង់អេឡិកត្រូនិក តាមប្រព័ន្ធបញ្ជរតែមួយជាតិ។

ក្រសួង-ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ អាចចេញសេចក្ដីណែនាំពីនីតិវិធីលម្អិតបន្ថែមតាមតម្រូវការចាំបាច់ ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តប្រព័ន្ធ។

**ប្រការ ៦.-**

ក្រុមអនុវត្តគម្រោងបញ្ជរតែមួយជាតិ មានភារកិច្ចសម្របសម្រួលនិងដោះស្រាយបញ្ហាបច្ចេកទេសនានា ពាក់ព័ន្ធនឹងការអនុវត្តប្រព័ន្ធបញ្ជរតែមួយជាតិ។

ក្នុងករណីប្រព័ន្ធពុំអាចដំណើរការបានដោយហេតុផលនានា ក្រសួង-ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ អាចចាត់ចែងអនុវត្តនីតិវិធីនៅក្រៅប្រព័ន្ធជាបណ្ដោះអាសន្ន តាមបទប្បញ្ញត្តិជាធរមាន។

**ប្រការ ៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៨.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាល អគ្គនាយកនៃអគ្គនាយកដ្ឋាន អគ្គាធិការ និងប្រធានអង្គភាពក្រោមឱវាទក្រសួង-ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារប្រកាសនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃអង្គារ ៨ រោច ខែ ជេស្ឋ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ២០១៩

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**ប្រធានគណៈកម្មាធិការដឹកនាំគម្រោងបញ្ជរតែមួយជាតិ**

**បណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល ÷**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្ដម លោកជំទាវឧបនាយករដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ៨ "ដើម្បីអនុវត្ត"
- សភាពាណិជ្ជកម្មកម្ពុជា "ដើម្បីសហការផ្សព្វផ្សាយ"
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

SK

លេខ ១១០ ចល.កសក

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើមលិខិតលេខ៥៧៥ សហវ.ប្រក ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៩ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងបញ្ជូនមកៈ

-ឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

"ដើម្បីជូនជ្រាប"

-ឯកឧត្តម លោក លោកស្រីប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-លោកប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត

"ដើម្បីជ្រាបនិងផ្សព្វផ្សាយ"

ថ្ងៃ ច័ន្ទ ៤កើត ខែ ទុតិយាសាឍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ២០១៩

**ត.ប រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**អគ្គលេខាធិការ**

**ស្រី វុឌ្ឍី**